## សន្តិសុខសង្គម

អត្ថប្រយោជន៍សន្តិសុខសង្គម មានផ្តល់ជូនអ្នកផ្តល់សេវាម្នាក់ៗអាយុ 18 ឆ្នាំ ឬលើសនេះ និងមិនមែនជាឪពុក/ម្តាយរបស់និយោជក/អ្នកទទួលសេវា។ អត្ថប្រយោជន៍នេះត្រូវផ្តល់ជូនអ្នក បើអ្នកក្លាយជាជនពិការទាំងស្រុង ឬចូលនិវត្តន៍ ហើយបំពេញបាននូវលក្ខខណ្ឌនៃសិទ្ធិទទួលបានអត្ថប្រយោជន៍ជាក់លាក់។ ត្រូវកាត់ប្រាក់ឈ្នួលរបស់អ្នក សម្រាប់បង់ចូលសន្តិសុខសង្គម (FICA)។ អត្ថប្រយោជន៍រួមមាន ប្រាក់ចូលនិវត្តន៍ ឬប្រាក់ពិការភាពប្រចាំខែ ដែលបង់ឲ្យអ្នក ឬជនក្នុងបន្ទុករបស់អ្នក។ អ្នកគួរទាក់ទងការិយាល័យរដ្ឋបាលសន្តិសុខសង្គមនៅមូលដ្ឋានរបស់អ្នក ដើម្បីទទួលបានព័ត៌មាន និង/ឬ ដាក់ពាក្យស្នើសុំសន្តិសុខសង្គម។ លេខទូរស័ព្ទ និងអាសយដ្ឋានរបស់ការិយាល័យនេះ មានលើទំព័រព័ណស ក្នុងសៀវភៅទូរស័ព្ទរបស់អ្នក ក្រោមចំណងជើង “United States Government, Social Security Administration” ។

## ពន្ធ MEDICARE

Medicare គឺជាអត្ថប្រយោជន៍ថែទាំសុខភាព និងព្យាបាល ដែលជាផ្នែកនៃកញ្ចប់អត្ថប្រយោជន៍សន្តិសុខសង្គមទាំងមូល។ កាលពីមុន ការកាត់ពន្ធ Medicare គឺជាផ្នែកមួយនៃការកាត់ពន្ធសន្តិសុខសង្គម (FICA)។ ឥឡូវនេះ ច្បាប់របស់រដ្ឋសហព័ន្ធតម្រូវឲ្យប្រាក់ពន្ធ និងចំនួនដែលត្រូវកាត់ ត្រូវរាយការណ៍ដោយឡែកពីគ្នា។ សំណួរទាក់ទងនឹងពន្ធ Medicare គួរបញ្ជូនទៅរដ្ឋបាលសន្តិសុខសង្គម។

## ការធានារ៉ាប់រងលើពិការ
## ភាពរបស់រដ្ឋ (SDI)

អត្ថប្រយោជន៍នៃធានារ៉ាប់រងពិការភាពរបស់រដ្ឋ ត្រូវផ្តល់ជូនអ្នក បើអ្នកក្លាយជាជនពិការ និងមិនអាចធ្វើសកម្មភាពជាប្រចាំបាន ហើយអ្នកបំពេញបាននូវលក្ខខណ្ឌនៃសិទ្ធិទទួលបានជាក់លាក់។ ប្រាក់ឈ្នួលរបស់អ្នក ត្រូវកាត់សម្រាប់បង់ចូល SDI។ អត្ថប្រយោជន៍នៃការធានារ៉ាប់រងលើពិការភាពរបស់រដ្ឋ ត្រូវផ្តល់ជូនសម្រាប់រយៈពេល 52 សប្តាហ៍។ អ្នកគួរទាក់ទងការិយាល័យនៅមូលដ្ឋានរបស់ក្រសួងអភិវឌ្ឍការងារនៃរដ្ឋ California (EDD) ដើម្បីទទួលបានព័ត៌មាន និង/ឬ ដាក់ពាក្យសុំការធានារ៉ាប់រងលើពិការភាពរបស់រដ្ឋ។ លេខទូរស័ព្ទ និងអាសយដ្ឋានការិយាល័យនេះ មានលើទំព័រព័ណស ក្នុងសៀវភៅទូរស័ព្ទរបស់អ្នក ក្រោមចំណងជើង “California State of, Employment Development Department”។

ប្រសិនបើអ្នកជាឪពុក/ម្តាយ ប្តី/ប្រពន្ធ ឬកូនរបស់បុគ្គល ដែលអ្នកផ្តល់សេវាឲ្យ អ្នកអាចជ្រើសរើសចូលរួមក្នុងកម្មវិធី SDI បាន តាមរយៈការដាក់ពាក្យសុំការធានារ៉ាប់រងលើពិការភាពរបស់រដ្ឋតាមការជ្រើសរើស។ ទម្រង់ពាក្យស្នើសុំការធានារ៉ាប់រងលើពិការភាពរបស់រដ្ឋតាមការជ្រើសរើស អាចរកបានពីបុគ្គលិកសង្គមកិច្ចនៃខោនធី។ ប្រសិនបើអ្នកចង់បានការធានារ៉ាប់រងតាមការជ្រើសរើសនេះ គេនឹងត្រូវកាត់ថ្លៃចំណាយចេញពីប្រាក់ឈ្នួលរបស់អ្នក។ អ្នកផ្តល់សេវាដទៃទាំងអស់ ត្រូវបានធានារ៉ាប់រងដោយស្វ័យប្រវត្តិចំពោះ SDI ប្រសិនបើអ្នកផ្តល់សេវាទាំងនោះមានប្រាក់ឈ្នួល IHSS ប្រចាំត្រីមាស លើសចំនួន $750។

## ការធានារ៉ាប់រងលើភាព
## គ្មានការងារធ្វើ (UI)

អត្ថប្រយោជន៍នៃការធានារ៉ាប់រងលើភាពគ្មានការងារធ្វើ (UI) អាចមានជូនអ្នក ប្រសិនបើអ្នកមិនមែនជាឪពុក/ម្តាយ ឬប្តី/ប្រពន្ធរបស់និយោជក /អ្នកទទួលសេវា ហើយក្លាយជាអត់មានការងារធ្វើ មានសមត្ថភាព និងពេលធ្វើការ និងអ្នកបំពេញបាននូវលក្ខខណ្ឌនៃសិទ្ធិទទួលបានជាក់លាក់។ គ្មានការកាត់ប្រាក់ឈ្នួលរបស់អ្នក សម្រាប់បង់ចូល UI ទេ។ អត្ថប្រយោជន៍នៃការធានារ៉ាប់រងលើភាពគ្មានការងារធ្វើ ផ្តល់ជូនសម្រាប់រយៈពេលអតិបរមា 26 សប្តាហ៍។ អ្នកគួរទាក់ទងការិយាល័យនៅមូលដ្ឋានរបស់ក្រសួងអភិវឌ្ឍការងារនៃរដ្ឋ California (EDD) ដើម្បីទទួលបានព័ត៌មាន និង/ឬ ដាក់ពាក្យសុំការធានារ៉ាប់រងលើភាពគ្មានការងារធ្វើ។ លេខទូរស័ព្ទ និងអាសយដ្ឋានការិយាល័យនេះ មានលើទំព័រព័ណស ក្នុងសៀវភៅទូរស័ព្ទរបស់អ្នក ក្រោមចំណងជើង “California State of, Employment Development Department”។

## សំណងកម្មករនិយោជិត

អត្ថប្រយោជន៍សំណងកម្មករនិយោជិតមានផ្តល់ជូនអ្នក បើអ្នករងរបួសពេលធ្វើការងារ ឬធ្លាក់ខ្លួនឈឺ ដោយសារតែការងារ ហើយអ្នកបំពេញបាននូវលក្ខខណ្ឌនៃសិទ្ធិទទួលបានជាក់លាក់។ គ្មានការកាត់ប្រាក់ឈ្នួលរបស់អ្នក សម្រាប់បង់ចូលក្នុងសំណងកម្មករនិយោជិតទេ។ បើអ្នករងរបួសក្នុងពេលបំពេញការងារ អ្នកគួរស្វែងរកការព្យាបាលសុខភាពភ្លាមៗ ហើយគួរជូនដំណឹងប្រាប់បុគ្គលិកសង្គមកិច្ចខោនធីរបស់និយោជក/អ្នកទទួលសេវារបស់អ្នក។ ទម្រង់ពាក្យសុំសំណងកម្មករនិយោជិត អាចរកបានពីបុគ្គលិកសង្គមកិច្ចខោនធី និងគួរប្រគល់មកឲ្យផ្នែកសង្គមកិច្ចខោនធីវិញ ពេលទម្រង់ពាក្យនេះបានបំពេញរួច។ ចំពោះព័ត៌មានបន្ថែមអំពីសំណងកម្មករនិយោជិត អ្នកអាចទូរស័ព្ទមកមន្ត្រីព័ត៌មាន និងជំនួយ លេខ 1-800-736-7401។

## ពន្ធកាត់ទុកលើចំណូល

ពន្ធរបស់រដ្ឋ និងរដ្ឋសហព័ន្ធលើចំណូលរបស់អ្នក អាចត្រូវកាត់ទុកពីប្រាក់ឈ្នួលរបស់អ្នក ប្រសិនបើអ្នកដាក់ពាក្យសុំ ហើយអ្នកបំពេញបាននូវលក្ខខណ្ឌនៃសិទ្ធិទទួលបានជាក់លាក់។ ការកាត់ទុកពន្ធលើចំណូលសម្រាប់អ្នកផ្តល់សេវាម្នាក់ៗ គឺជាការស្ម័គ្រចិត្តសុទ្ធសាធ។ បើអ្នកចង់ឲ្យកាត់ទុកពន្ធរបស់រដ្ឋ និងរដ្ឋសហព័ន្ធលើចំណូល ចេញពីប្រាក់ឈ្នួលរបស់អ្នក សូមបំពេញទម្រង់ពន្ធកាត់ទុកលើចំណូល (W-4) រួចសូមផ្ញើតាមប្រៃសណីយ៍មកផ្នែកសង្គមកិច្ចនៃខោនធីរបស់អ្នក។ ប្រសិនបើអ្នកមិនចង់ឲ្យកាត់ទុកពន្ធរបស់រដ្ឋ និង/ឬរដ្ឋសហព័ន្ធលើចំណូលចេញពីប្រាក់ឈ្នួលរបស់អ្នក អ្នកនៅតែត្រូវបានតម្រូវឲ្យដាក់លិខិតប្រកាសពន្ធនៅចុងឆ្នាំ ហើយអាចបង់ពន្ធលើប្រាក់ចំណូលរបស់អ្នក។ អ្នកគួរទាក់ទងបុគ្គលិកសង្គមកិច្ចនៃខោនធីរបស់និយោជក/អ្នកទទួលសេវារបស់អ្នក បើអ្នកត្រូវការទម្រង់ W-4 បន្ថែម បើអ្នកចាំបាច់ត្រូវផ្លាស់ប្តូរការកាត់ទុកពន្ធ ឬបើអ្នកចាំបាច់ត្រូវកំណត់ពីឋានៈនៃការកាត់ទុកពន្ធរបស់អ្នក។

អ្នកគួរទាក់ទងការិយាល័យនៅមូលដ្ឋានរបស់ California Franchise Tax Board (FTB) ដើម្បីបានព័ត៌មានបន្ថែម អំពីការកាត់ទុកពន្ធរដ្ឋលើចំណូល។ លេខទូរស័ព្ទ និងអាសយដ្ឋានការិយាល័យ មានលើទំព័រព័ណស ក្នុងសៀវភៅទូរស័ព្ទរបស់អ្នក ក្រោមចំណងជើង “Californa Franchise Tax Board”។ អ្នកគួរទាក់ទងការិយាល័យនៅមូលដ្ឋានរបស់ Internal Revenue Service (IRS) ដើម្បីបានព័ត៌មានអំពីការកាត់ទុកពន្ធរបស់រដ្ឋសហព័ន្ធលើចំណូល។ លេខទូរស័ព្ទ និងអាសយដ្ឋានការិយាល័យ មានលើទំព័រព័ណស ក្នុងសៀវភៅទូរស័ព្ទរបស់អ្នក ក្រោមចំណងជើង “United States Government, Internal Revenue Service”។

## ក្រេឌីតចំណូលដែលរកបាន
## (EIC)

អ្នកអាចមានសិទ្ធិទទួលបាននូវក្រេឌីតចំណូលដែលរកបាន (EIC)។ ដើម្បីស្វែងយល់អំពី EIC និងថាតើអ្នកមានសិទ្ធិទទួលបាន ឬយ៉ាងណា សូមអានសេចក្តីណែនាំអំពីការបំពេញទម្រង់ W-5 (លិខិតបញ្ជាក់ពីការបង់ឲ្យមុនចំពោះក្រេឌីតចំណូលដែលរកបាន) ដោយយកចិត្តទុកដាក់។ បើអ្នកមានសិទ្ធិទទួលបាន EIC អ្នកអាចជ្រើសរើសទទួលបានក្រេឌីតនេះជាមុន ជំនួសការរង់ចាំ រហូតដល់អ្នកដាក់លិខិតប្រកាសពន្ធ។ អ្នកគួរទាក់ទងការិយាល័យមូលដ្ឋានរបស់ Internal Revenue Service ឬទីប្រឹក្សាពន្ធរបស់អ្នក ដើម្បីបានព័ត៌មានអំពី EIC។

## សូមស្វាគមន៍មកកាន់ការងាររបស់អ្នកជាអ្នកផ្តល់សេវាគាំពារនៅផ្ទះ (IHSS)

ខិតប័ណ្ណនេះរៀបរាប់សង្ខេបអំពីអត្ថប្រយោជន៍ ដែលអាចផ្តល់ជូនអ្នក និងការទទួលខុសត្រូវរបស់អ្នកលើពន្ធចំណូល។ សូមអានខិតប័ណ្ណនេះដោយយកចិត្តទុកដាក់។ ម្យ៉ាងទៀត សូមចងចាំថា និយោជករបស់អ្នកគឺជាអ្នកទទួលសេវា IHSS ដែលបានជួលអ្នកឲ្យផ្តល់សេវានេះ មិនមែនរដ្ឋ California ឬ ផ្នែកសង្គមកិច្ចនៃខោនធី (CWD) ទេ។ រដ្ឋ California ចេញផ្សាយនូវខិតប័ណ្ណនេះ និងបើកប្រាក់ឈ្នួលឲ្យអ្នក តាងនាមនិយោជករបស់អ្នក ហើយ CWD ជាអ្នកចាត់ចែងលើលិខិតស្នាមទាំងអស់។

សូមទាក់ទង CWD នៅពេលណាក៏ដោយ ដែលអ្នកមានសំណួរ ទាក់ទងប្រាក់ឈ្នួល និងសន្លឹកម៉ោងធ្វើការ។ ត្រូវចុះហត្ថលេខា និងកាលបរិច្ឆេទនៅលើសន្លឹកម៉ោងធ្វើការរបស់អ្នកជានិច្ច បន្ទាប់ពី (មិនមែនមុន) ដំណាច់នៃរយ:ពេលបើកប្រាក់ ហើយត្រូវឲ្យនិយោជករបស់អ្នកចុះហត្ថលេខា និងកាលបរិច្ឆេទលើសន្លឹកម៉ោងធ្វើការនោះផងដែរ បន្ទាប់មក ត្រូវផ្ញើសន្លឹកម៉ោងធ្វើការនោះមក CWD តាមប្រៃសណីយ៍ ទៅកាន់អាសយដ្ឋាន ដែលបង្ហាញនៅជ្រុងខាងស្តាំនៃសន្លឹកម៉ោងធ្វើការ ដើម្បីជៀសវាងការយឺតយ៉ាវក្នុងការទទួលបានប្រាក់ឈ្នួលរបស់អ្នក។ ត្រូវចង់ចាំថា៖ ត្រូវជូនដំណឹង CWD ជានិច្ចអំពីការផ្លាស់ប្តូរអាសយដ្ឋាន និង/ឬលេខទូរស័ព្ទរបស់អ្នក។

**បុគ្គលិកសង្គមកិច្ចនៃខោនធីរបស់ខ្ញុំ គឺ៖:**

ឈ្មោះ ______________________________

____________________________________

អាសយដ្ឋាន __________________________

____________________________________

____________________________________

ទូរស័ព្ទ៖ ____________________________

____________________________________

**ខោនធី៖**

ដើម្បីទទួលបានព័ត៌មានអំពី IHSS
សូមទូរស័ព្ទមកផ្នែកសង្គមកិច្ចនៃ
ខោនធីនៅមូលដ្ឋាន។

**STATE OF CALIFORNIA**

**HEALTH AND HUMAN SERVICES AGENCY**

**DEPARTMENT OF SOCIAL SERVICES**

PUB 104 (12/06)

# សេវាគាំពារនៅផ្ទះ (IN-HOME SUPPORTIVE SERVICES)

# ព័ត៌មានអំពីអត្ថប្រយោជន៍ និង សេវារបស់អ្នកផ្តល់សេវាម្នាក់ៗ

CDSS

CALIFORNIA DEPARTMENT OF SOCIAL SERVICES